# អាកប្បកិរិយានៃជំងឺផ្លូវចិត្ត មួយចំនួនបង្កបញ្ហា

# Behaviors that cause concern

# វត្ថុបំណងរួម

១.រៀបរាប់ពី អាកប្បកិរិយាបុគ្គលដែលមាន
 លក្ខណៈកាចឬហឹង្សា

២.រៀបរាប់ពី អាកប្បកិរិយាបុគ្គលដែលមានការ
 សង្ស័យ មានជំនឿប្លែក ឬ ឮសំលេង

៣.រៀបរាប់ពី អាកប្បកិរិយាបុគ្គលដែលគិតចង់សំលាប់
 ខ្លួនឬ ព្យាយាមសំលាប់ខ្លួន

៤.រៀបរាប់ពីមនុស្សចាស់ ដែលមានបញ្ហា
 អាកប្បកិរិយា

# វត្ថុបំណងទី១

រៀបរាប់បុគ្គលដែលមានលក្ខណៈកាចឬហឹង្សា



# Aggressive behavior

- Aggressive behavior is behavior that causes physical or emotional harm to others, or threatens to. It can range from verbal abuse to the destruction of a victim’s personal property. People with aggressive behavior tend to be irritable, impulsive, and restless.

  http://www.healthline.com/health/aggressive-behavior

# Violence

- Using or involving the use of physical force to cause harm or damage to someone or something : showing violence. : caused by physical force or violence.

www.merriam webster.com/dictionary/violent

# បុគ្គលដែលមានលក្ខណៈកាចឬហឹង្សា

- លក្ខណៈកាចឬហឹង្សាជាលក្ខណៈធ្វើអោយមនុស្ស មានការឈឺចាប់
- កាចដោយប្រើពាក្យសំដី



# បុគ្គលមានលក្ខណៈកាចឬហឹង្សា(ត)

- កាចដោយស្រែកគំហក ឬ សំដីគំរោះគំរើយ
- កាច ដោយបំពានផ្នែករាងកាយ ដូចជា ការក្តិច វាយដំ ទះកំភ្លៀង
- ធ្ងន់ធ្ងរ ជាងនេះ ដូចជា ការប្រើ អាវុធ ដំបង កាំបិត ឬ កាំភ្លើង

# សំណួរ

ហេតុអ្វីបានជាមនុស្សមានជំងឺផ្លូវ ចិត្ត  មានលក្ខណៈកាច?

# ចំលើយ

- វាមិនកើតមានចំពោះតែជំងឺផ្លូវចិត្ត ទេ
- ការស្តាប់ឮសំលេង ហើយខឹង ដោយសារអ្នកជំងឺគិតថា សំលេងនោះ និយាយអាក្រក់ពីខ្លួនគាត។
- មានការជឿខុស: គិតថា មានមនុស្សដទៃ កំពុងរៀបចំផែនការ សំលាប់គាត់ ហើយធ្វើអោយគាត់ភ័យ ដូច្នេះហើយ ធ្វើអោយគាត់មានប្រតិកម្ម តបវិញ។

# ចំលើយ (គ)

- ត្រូវ គេបញ្ឈប់ផែនការ និង ការស្រមើស្រមៃ:

  អ្នកជំងឺកំពុងមានផែនការដ៏ធំមួយ ហើយ ចង់ធ្វើអ្វីៗ

  អោយ មានការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងជីវិត របស់ខ្លួន

  តែត្រូវ គេប្រាប់ថាមិនអាចទៅរួច ។ វាអាចកើតឡើងចំពោះ

  អ្នកជំងឺមេនៀ (Mania).

# Case study about mania

ខ្ញុំធ្លាប់ទទួលអារម្មណ៍ថា បើខ្ញុំមានថាមពលខ្លាំង វា
មិនត្រូវការដេកអ្វីទាំងអស់ ប៉ុន្តែការពិតខ្ញុំពិបាក
ដេកណាស់នៅថ្ងៃនោះ៕ ខ្ញុំប្រញាប់ប្រញាល់ក្នុងការ
រៀបចំប្រធានបទ និង គំរោងផែនការជាច្រើន ។

- I used to feel as if I had so much energy that not need to sleep at all. In fact, I hardly sleep in those days. I would rush about with all my schemes and plans.

# Case study about mania (cont)

- ប៉ុន្តែខ្ញុំមិនដែលធ្វើវាអោយចប់ពិតប្រាកដទេ។ខ្ញុំ ធ្លាប់ទប់កំហឹងមិនបាននៅពេលអ្នកណាម្នាក់ព្យាយាមបញ្ឈប់ខ្ញុំ។ នៅពេលមួយនោះខ្ញុំធ្លាប់ មានជំលោះយ៉ាងខ្លាំងជាមួយដៃគូររកស៊ីពីផែនការដ័ឆ្កួតរបស់ខ្ញុំ។ But I never really managed to finish any of them properly. I used to lose my temper if any one tried to stop me. Once I got into big fighting with my business partner over one of my crazy scheme

# Case study about mania (cont)

- ប៉ុន្តែនៅពេលខ្ញុំមានអារម្មណ៍ឡើងខ្លាំង ខ្ញុំមិនដែលទទួលស្គាល់ថា ខ្លួនឯងខុសទេ ។ ខ្ញុំពេលខ្លះទទួលអារម្មណ៍ថាខ្ញុំមានថាមពលពិសេសដែលអាចព្យាបាលអ្នកដទៃបាន។ ចំណុចខ្សោយនៃជំងឺរបស់ខ្ញុំគឺត្រូវតែចាយលុយច្រើននៅពេលដែលគ្រួសារខ្ញុំ កំពុងតែគ្មានលុយ។
- But when I am high , I never realised how wrong I was. I even felt sometimes that I had special power to heal others. the worst thing about my illness how was I would spend so much money that I almost bankrupt the family.

# ចំលើយ (cont)

- មិនអាចផឹកស្រាបានទាន់ពេល:

នៅពេលអ្នកកំពុងញៀនស្រា ឬ ថ្នាំញៀនអ្នកមាន

អារម្មណ៍មិនសុខស្រួលក្នុងរាងកាយ ព្រោះតែសេចក្តីត្រូវការ

ដូច្នេះបើត្រូវបានគេបញ្ឈប់ នោះនាំអោយ

→ អ្នកខឹង នឹងទៅជាកាច ។

# មានការភ្លេចភ្លាំង

- អ្នកមានការលំបាកចងចាំ  អ្នកមិនដឹងថា  អ្នកនៅកន្លែងណា
- មិនចាំថ្ងៃណា  ឬ  ខែណា  ឬអ្នកណាកំពុងនិយាយជាមួយអ្នក

អ្នកភ័យខ្លាច  និងគិតថាអ្នកត្រូវការពារខ្លួន ទៅជនចំលែកនោះ

អ្នកក្លាយជា  ខឹង  និង  កាច

# មូលហេតុនៃការភ្លេចភ្លាំង

- ទទួលទានស្រាច្រើនពេក
- ជាតិស្ករក្នុងឈាមថយចុះ
- រលាកខួរក្បាល
- ខូចខួរក្បាល

# មានជំងឺផ្លូវចិត្ត

- មិនខុសពីមនុស្សជា
- អ្នកជំងឺផ្លូវចិត្ត ឆាប់អន់ចិត្ត ហើយក្លាយជាខឹង
- ករណីធ្ងន់ធ្ងរ នាំអោយបុគ្គលក្លាយជាកាច និង ប្រើហឹង្សា

## តើត្រូវដោះស្រាយបញ្ហានេះយ៉ាងដូចម្តេច?

# សំណួរសួរទៅក្រុមគ្រួសារ ឬ មិត្តភក្តិ

- តើបុគ្គលមានអាការៈមួម៉ៅ ជាច្រើនថ្ងៃហើយ?
- តើមានអ្វីកើតឡើងជាក់លាក់ ដូចជាការឈ្លោះប្រកែកគ្នា ពីការផឹកស្រា
- អាការៈកាច ដោយមិនដឹងមូលហេតុ កំរកើតមានណាស់
- តើបញ្ហានេះកើត មានពីមុនដែរឬទេ ? ប្រសិនជាធ្លាប់កើតមាន

  នោះវានឹងអាចកើតមានឡើងម្តងទៀត

# សំណួរសួរទៅក្រុមគ្រួសារ ឬ មិត្តភក្តិ (ត)

- តើបុគ្គលធ្លាប់មានជំងឺផ្លូវចិត្តពីមុនដែរឬទេ?

  តើគាត់កំពុងព្យាបាលដែរឬទេ?

- តើបុគ្គលនោះ ជឿទុកចិត្តអ្នកណា?

  បុគ្គលនោះនឹងធ្វើអោយអ្នកដែលខឹងនេះ ស្ងប់ចិត្តបាន។

- តើបុគ្គលនោះ មានញៀនស្រា ឬ ថ្នាំញៀនដែរឬទេ?

# សំណួរសួរបុគ្គលដែលកាច

- គួរសួរកហេតុផលដែលធ្វើអោយបុគ្គលកាច
- សួរគាត់ តើគាត់នៅតែខឹងដែរឬទេ? ប្រសិនជាគាត់នៅតែខឹង
- ស្នើរទៅគាត់ តើអ្នកគួរបន្តសំណួរទៀតឬ គាត់ចង់

  នៅម្នាក់ឯងបន្តិចសិន ។
- តើគាត់កំពុងមានភាពតានតឹងចិត្តដែរឬទេ ?

# សំណួរសួរទៅរកបុគ្គលដែលកាច (ត)

- សង្កេតអាកប្បកិរិយាប្លែកៗរបស់បុគ្គលដែលកាច
- សួរគាត់ តើអ្នកគិតថា មានអ្នកដទៃ កំពុងនៅជុំវិញអ្នកទេ?
- ប្រសិនជាមាន តើមនុស្សកំពុងធ្វើអ្វី ? តើពួកគេមាននិយាយអាក្រក់ពីអ្នកដែរឬទេ?
- → ចង់ដឹងថា

តើបុគ្គលនោះមានរោគសញ្ញាវិកលចរិកដែរឬទេ?

# សំណួរសួរទៅរកបុគ្គលដែលកាច (ត)

- តើអ្នកធ្លាប់ឮមនុស្សនិយាយអាក្រក់ពីអ្នកដែរឬទេ?
- តើអ្នកមានឮសំលេងមនុស្សនិយាយ ក្នុងត្រចៀក អ្នក

  នៅពេលមិនមានមនុស្សនៅក្បែរដែរឬទេ?
- Hallucination មមាល ជាសញ្ញាសំខាន់បំផុតនៅក្នុងជំងឺវិកលចរិក

  មានទំនាក់ទំនងដោយការប្រើ គ្រឿងញៀន ឬការផឹកស្រា

# លំនាំក្នុងការសំភាសន៍

- ត្រូវដឹងសញ្ញាដែលហៀបនឹងកើតមានហឹង្សា:
- និយាយខ្លាំងៗ ឬ មានលក្ខណៈបំពារបំពានគំរាមគំហែង
- ក្តាប់ដៃ
- ដកដង្ហើមញាប់
- ទះតុ ឬ វាយជញ្ជាំង

# លំនាំក្នុងការសំភាសន៍ (ត)

- ប្រាប់អោយដឹងថា សំដីនិយាយរបស់បុគ្គលគ្មានន័យ ឬ និយាយយ៉ាងញាប់ដែលជាសញ្ញាបង្ហាញអោយដឹងថា រាងកាយទទួលជាតិពុលច្រើន ឬ ជាសញ្ញានៃជំងឺវិកលចរិត
- ដឹងពីក្លិនរបស់សុរា ឬ ស្នាមម្ជុលចាក់ថ្នាំ (សញ្ញានៃការប្រើថ្នាំញៀន)
- សង្កេតមើលដំណើរទ្រេតទ្រោត (បាត់លំនឹង) ឬ សំដីច្រអូសដែលជាសញ្ញា បង្ហាញពីការមានជាតិពុលក្នុងខ្លួន ឬ ដោយថ្នាំញៀន ។

# លំនាំក្នុងការសំភាសន៍ (ត)

- លោកអ្នកត្រូវយកចិត្តទុកដាក់ពីអារម្មណ៍របស់ខ្លួនឯង ប្រសិនជា អ្នកមានអារម្មណ៍ភ័យខ្លាច អ្នកត្រូវបញ្ឈប់កិច្ចសំភាសន៍ **ដោយពិនិត្យ អោយច្បាស់ថា ទាំងអ្នក និង មនុស្សដែលអ្នកសំភាសន៍មានច្រក ចេញបានពីបន្ទប់ដូចគ្នា**
- អ្នកគប្បីនិយាយអោយច្បាស់ និងមានសំលេងស្រាល មិនត្រូវស្រែកដាក់បុគ្គលដែលអ្នកសួរសំភាសន៍នោះ បំណងអោយស្ងៀមស្ងាត់ឡើយ។

# តើអ្វីដែលត្រូវ ធ្វើជាបន្ទាន់

- ជាដំបូងត្រូវព្យាយាមនិយាយ និងពន្យល់អោយបុគ្គលស្ងប់ អារម្មណ៍និងស្តាប់ការនិយាយរបស់គាត់
- មិនត្រូវប្រញាប់ធ្វើអោយស្ថានភាពស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកភ្លាមទេ
- អ្នកត្រូវធ្វើយ៉ាងណាអោយគាត់ព្រម ទទួលថ្នាំរំងាប់អារម្មណ៍
- Lorazepam 1-2 mg
- Diazepam 5-10mg
- Antipsychotic Haloperidol 5 mg or chlorpromazine 50-100mg

# តើអ្វីដែលត្រូវ ធ្វើជាបន្ទាន់ (ត)

- ប្រសិនជាគាត់មិនព្រមលេបថ្នាំ ហើយមានលក្ខណៈរំខានធ្ងន់ធ្ងរ នោះអ្នកត្រូវចាប់គាត់ចាក់ថ្នាំ
- ត្រូវត្រៀមថ្នាំជាមុន ដូចជា
- Diazepam 5-10mg I/M or I/V slow
- Haloperidol 5 mg -10 mg I/M
- chlorpromazine 25-100 mg I/V

# តើពេលណាត្រូវបញ្ជូន ?

- ប្រសិនជាសង្ស័យថា ការបង្កហឹង្សានោះ ជាប់ទាក់ទងនឹងភាពវង្វេងវង្វាន់ ឬ របួសក្បាល ឬ ជំងឺខួរក្បាលផ្សេងទៀត អ្នកត្រូវបញ្ជូនបុគ្គលនោះទៅមន្ទីរពេទ្យទូទៅ ។ ជាការប្រសើរ គប្បីមានបុគ្គលិកសុខភាពជូនគាត់ទៅ ។

# អ្វីដែលត្រូវ ធ្វើជាបន្ត?

បញ្ជូនគាត់ទៅកាន់គ្រូពេទ្យ ឯកទេសវិកលវិទ្យា ករណីគាត់មានជំងឺវិកលចរិក ដែលត្រូវការព្យាបាលបន្ត

# វត្ថុបំណងទី២

បុគ្គលដែលមានការសង្ស័យ មានជំនឿប្លែក ឬ

ពូសំលេង

# ការឮសំលេង

- នៅពេលដែលមនុស្សម្នាក់ ស្តាប់ឮសំលេងមនុស្សដទៃកំពុង និយាយ ដោយគ្មានអ្នកណានៅជិតនោះ   លក្ខណៈ បែបនេះ គេហៅថា **មមាល** **Auditory hallucination** ។
- ជារឿយៗ សំលេងទាំងនោះ មានលក្ខណៈអវិជ្ជមាន ដែលនាំអោយ បុគ្គលមិនសប្បាយចិត្ត ។

- **Illusion** = Mis intepretation
- **Hallucination = False Perception**
- **Delusion = False Belief**

# ហេតុអ្វីបានជាមនុស្សមានលក្ខណៈបែបនេះ

លក្ខណៈបែបនេះ វាមិនកើតមានញឹកញាប់ទេ

វាកើតឡើងចំពោះមនុស្សដែលមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ ដូចជា :

– ជំងឺ ស្គីហ្សូហ្វ្រេនៀ ដែលមានប្រវត្តិជំងឺលើសពី ៦ ខែ

– ជំងឺវិកលចរិតដោយសារគ្រឿងញៀន

- Manic depressive illness

# តើមនុស្សធម្មតាមានពួសំលេងដែរឬទេ?

- នៅក្នុងសហគមន៍ខ្លះ មានបុគ្គលមួយចំនួន អះអាងថា ពួកគេអាចនិយាយទាក់ទងជាមួយខ្មោច បិសាច បាន ដូច្នេះពួកគេអាចស្តាប់ពួសំលេង ខ្មោច បិសាច ឬព្រះអាទិទេព ។ ពួកគេក៏មានជំនឿថា ព្រះអាទិទេព ឬ បិសាចកំពុងខឹង អ្នកណាម្នាក់។

# តើមនុស្សធម្មតាមានព្យួសំលេងដែរឬទេ?

- ការព្យួសំលេងនេះ គេមិនរកការព្យាបាលទេ គេប្រើបទពិសោធន៍ទាំងនោះសំរាប់សុខភាពរបស់គេផ្ទាល់ និងជួយអ្នកដទៃដែលមានបញ្ហាផ្លូវចិត្តទៀតផង។ ការព្យួនេះមិនមែនជាការព្យួសំលេងដូចក្នុងជំងឺផ្លូវចិត្តទេ ។យើងគិតថាជាជំងឺលុះត្រា តែវា រំខានទៅលើជីវិតបុគ្គល និងគ្រួសាររបស់គេ។

# វត្ថុបំណងទី៣

រៀបរាប់ពីអាកប្បកិរិយា
បុគ្គលដែលចង់សម្លាប់ខ្លួន
ឬព្យាយាមសម្លាប់ខ្លួន

# ការសម្លាប់ខ្លួន

គឺជាការបញ្ចប់ជីវិតខ្លួនឯង។

ការសម្លាប់ខ្លួនចែកជា:

- មានគំនិតចង់សម្លាប់ខ្លួន
- ព្យាយាមសម្លាប់ខ្លួន
- សម្លាប់ខ្លួនបានសម្រេច

# Suicide

- Suicide        Thought or  Idea
- Suicide        Attempt
- Complete    Suicide or Suicide death

# តួនាទីបុគ្គលិកសុខាភិបាល

ត្រូវស្វែងយល់ពីបុគ្គលដែលចង់សម្លាប់ខ្លួន ឬព្យាយាមសម្លាប់ខ្លួននិងផ្តល់ការគាំទ្រ



# ហេតុអ្វីបុគ្គលចង់បញ្ចប់ជីវិតខ្លួនឯង?



# Video clip on suicide

- https://fb.watch/ooeaXwhBfz/

- មានមនុស្សជាច្រើន   នៅពេលខ្លះគិតថា
  រស់នៅប៉ុណ្ណឹងល្មមហើយ
- ប៉ុន្តែក៏នៅមានមនុស្សជាច្រើនដែរជួបស្ថានភាព
លំបាកនានាក្នុងជីវិត ហើយពួកគេបន្តរស់តទៅទៀត ។

# មូលហេតុចំបងនៃការធ្វើអត្តឃាត

- ជំងឺធ្លាក់ទឹកចិត្ត ជាមូលហេតុចំបងនៃការធ្វើអត្តឃាត ។ ជំងឺធ្លាក់ទឹកចិត្តអាចធ្វើអោយបុគ្គល មានអារម្មណ៍ធ្លាក់ចុះយ៉ាងខ្លាំង បាត់បង់ការចាប់អារម្មណ៍ក្នុងជីវិត និង សេចក្តីសង្ឃឹមចំពោះអនាគត។

# មូលហេតុចំបងនៃការធ្វើអត្តឃាត (ត)

- ការប្រើសុរា និង ថ្នាំញៀន
- បញ្ហាសុខភាពរ៉ាំរ៉ៃ
- ជំងឺផ្លូវចិត្តធ្ងន់ធ្ងរ
- ទំនាក់ទំនងរស់នៅមិនល្អ

# មូលហេតុចំបងនៃការធ្វើអត្តឃាត (ត)

- ភាពក្រីក្រ និងការលំបាកផ្នែកសេដ្ឋកិច្ច
- ការបាត់បង់មនុស្សជាទីស្រលាញ់ ការសោកសង្រេង
- គ្មានមិត្តភក្តិពិគ្រោះយោបល់ និង ចែករំលែកអារម្មណ៍

# ភេទ និង ការធ្វើ អត្តឃាត

- ស្ត្រីមានការព្យាយាមសំលាប់ខ្លួន ច្រើនជាងបុរស ពីព្រោះស្ត្រីភាគច្រើន មានជំងឺធ្លាក់ទឹកចិត្ត
- ការសំលាប់ខ្លួនបានជោគជ័យ ភាពច្រើនជាបុរស។

- តើត្រូវ ដោះស្រាយ បញ្ហានេះយ៉ាង ដូចម្តេច?

# សំណួរទៅកាន់គ្រួសារ ឬ មិត្តភក្តិ

- តើមានអ្វីកើតឡើង?
- តើជាការប៉ុនប៉ងដែលបង្កគ្រោះថ្នាក់ដែរឬទេ?
- ប្រសិនជាមនុស្សម្នាក់គាត់ព្យាយាមចងក ឬ ផឹកថ្នាំពុល (ថ្នាំសំលាប់សត្វល្អិត) នោះជាការប៉ុនប៉ងបង្កគ្រោះថ្នាក់ ។
- តែបើគ្រាន់តែ យកបុិចឆូតដៃ នោះមិនសូវមានគ្រោះថ្នាក់ទេ

# សំណួរទៅកាន់បុគ្គលដែលសំលាប់ខ្លួន

តើមានអ្វីកើតឡើងចំពោះអ្នក ?

តើអ្នកមានគំនិតចង់សំលាប់ខ្លួនដែរឬទេ? ហេតុអ្វី?

តើអ្នកមានរៀបចំគំរោងដែរឬទេ?

ចាប់តាំងពីពេលណាមក?

តើអ្នកបានប្រាប់អ្នកដទៃពីគំរោងនោះដែរទេ ?

- ការរៀបចំគំរោងដោយប្រុងប្រយត្ន័ ដោយលាក់កំបាំងជាសំងាត់មានលក្ខណៈធ្ងន់ធ្ងរ ។

- តើអ្នកមានអារម្មណ៍ធ្លាក់ទឹកចិត្តទេ ពេលថ្មីៗនេះ តើអ្នកមិនចាប់អារម្មណ៍ក្នុងការរស់នៅមែនទេ? ការសួរបែបនេះ ផ្តោតទៅលើជំងឺធ្លាក់ទឹកចិត្ត

# ការពិនិត្យបុគ្គលដែលប៉ុនប៉ង់សំលាប់ខ្លួន

- ជាគោលការណ៍អ្នកត្រូវបញ្ជូនបុគ្គលដែលចង់សំលាប់ខ្លួនទៅមន្ទីរពេទ្យដែលនៅជិត (ប្រសិនជាអាច)
- ករណីចងក ចាក់នឹងវត្ថុអ្វីមួយ បាញ់ដោយកាំភ្លើង , កាត់ ឬដុត បែបនេះត្រូវសង្គ្រោះបន្ទាន់សិន   មុនបញ្ជូនទៅមន្ទីរពេទ្យ អ្នកត្រូវពិនិត្យ ដង្ហើម សំពាធឈាម និង ជីពចរ។ ព្យួរសេរ៉ូម បើបុគ្គលមានសំពាធឈាមទាប។
- ករណីប្រើថ្នាំពុលសត្វល្អិតហួសកំរិត ឬ សារធាតុផ្សេងទៀត៖
- ត្រូវធ្វើអោយគាត់ក្អួតតាមវិធីផឹកទឹកអំបិលប្រៃខ្លាំង
- ផ្តល់ទឹកកំហាប់នៃម្សៅធ្យូង ដើម្បីស្រូបជាតិពុល

# ការសំលាប់ខ្លួនអាចជាឧក្រិដ្ឋកម្ម

- នៅប្រទេសខ្លះការសំលាប់ខ្លួនជាបទឧក្រិដ្ឋ ជាករណីផ្លូវច្បាប់ ឬ ករណីដែលនគរបាលត្រូវតាមដាន។
- បើអ្នកពិនិត្យដឹងថាការប៉ុនប៉ងសំលាប់ខ្លួនទាក់ទងនឹងភាពតានតឹងចិត្ត អ្នកពុំចាំបាច់រាយការណ៍ទៅប៉ូលិសទេ
- បើការប៉ងសំលាប់ខ្លួនរបស់ស្ត្រីទាក់ទងនឹងការធ្វើបាបរបស់ប្តី ឬ សាច់ថ្លៃ នោះអ្នកអាចរាយការណ៍បាន បើមានការយល់ព្រមពីប្រពន្ធ

# ការជួយអ្នកដែលចង់សំលាប់ខ្លួន

- Reduce poverty
- Take a way the availability of  tools which clients can use to commit suicide.
- Reduce level depression of the client.
- Suicide counseling.
-  Let client to think the reason that he/she want to live ( divert thinking)

# វត្ថុបំណងទី៦

រៀបរាប់ពីមនុស្សចាស់ដែលមានបញ្ហាអាកប្បកិរិយា



- លក្ខណៈវង្វេងច្រឡំ និងកាចអាចកើតមានចំពោះមនុស្សចាស់
- បងប្អូនអ្នកជំងឺខ្លះ ត្អូញត្អែរថាមនុស្សចាស់បានប្រព្រឹត្តផ្លូវភេទមិនសមរម្យ ឬទទួចដើរចេញក្រៅផ្ទះ ទោះបីជាគាត់មានលក្ខណៈវង្វេងវង្វាន់ក្តី
- អាកប្បកិរិយាផ្សេងទៀតគឺ មនុស្សចាស់ផ្តាច់ខ្លួនពីគេឯងនិងមិនចាប់អារម្មណ៏ជាមួយអ្វីៗឡើយ។លក្ខណៈបែបនេះវាមិនមែនជាបញ្ហាទេ តែវាជាជំងឺផ្លូវចិត្តម្យ៉ាង។

# ហេតុអ្វីបានជាមនុស្សចាស់មានលក្ខណៈបែបនេះ?

- មានហេតុផល៤យ៉ាង៖
- ១.ជំងឺធ្លាក់ទឹកចិត្ត៖លក្ខណៈទូទៅរបស់មនុស្សចាស់គឺផ្ដាច់ខ្លួនចេញពីគេក្នុងជីវិតរស់នៅប្រចាំថ្ងៃ មិនចង់ទទួលទានអាហារ សំរាន្តមិនលក់ និងត្អូញត្អែរពីបញ្ហារាងកាយ។ មនុស្សចាស់ខ្លះចង់ធ្វើអត្តឃាត
- ២.ការរវើរវាយ ឬវង្វេងវង្វាន់៖មានសភាពស្រួចស្រាល់ហើយអាកប្បកិរិយាអាចនឹងកើតឡើងក្នុងរយៈពេល២ទៅ៣ ថ្ងៃ ។គាត់អាចមានមមាល និងជ្រួលជ្រាល

# ហេតុអ្វីបានជាមនុស្សចាស់មានលក្ខណ:បែបនេះ?(ត)

- ៣.វិកលចរិក៖កើតឡើងលើមនុស្សចាស់ដែលមានជំងឺវង្វេងវង្វាន់ភ្លេចភ្លាំង (Dementia) ដែលគាត់មានរោគសញ្ញា មមាល និង ចេះតែសង្ស័យ
- ៤. ជំងឺវង្វេងស្មារតី៖កើតលើវ័យចាស់ពិសេសចាប់ពី ៦៥ ឆ្នាំឡើងទៅ ។សញ្ញាដំបូងនៃជំងឺគឺបញ្ហានៃការចងចាំ។
- បុគ្គលិកសុខាភិបាលងាយចាប់អារម្មណ៍ពីជំងឺនេះដោយសារបញ្ហាអាកប្បកិរិយា។ជំងឺវង្វេងស្មារតី (Dementia) ជាជំងឺដែលខួរក្បាលចុះថយសមត្ថភាពជាលំដាប់។វាមិនមានការព្យាបាលអោយជាដាច់ទេ

# ឯកសារសំអាង

- ទីណាគ្មានវេជ្ជបណ្ឌិតសុខភាពផ្លូវចិត្ត ទំព័រ ៧៧ ដល់ ១១៦
- Where there is no psychiatrist Pages

- http://www.healthline.com/health/aggressive-behavior
- www.merriamwebster.com/dictionary/violenuupdated